## រាជរដ្ឋាភិបាលកម្ពុជា

## ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# សៀវភៅណែនាំ
# ស្តីពី
# ពន្ធលើប្រាក់បៀវត្ស

ឆ្នាំ ២០១៣

រៀបចំ និង បោះពុម្ពផ្សាយដោយ

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រក្សាសិទ្ធិគ្រប់បែបយ៉ាង

| មាតិកា | ទំព័រ |
|---|---|
| តើពន្ធលើប្រាក់បៀវត្សគឺជាអ្វី? | ១ |
| តើនរណាជាអ្នកជាប់ពន្ធនិវាសនជន? | ១ |
| តើនរណាជាអ្នកជាប់ពន្ធអនិវាសនជន? | ១ |
| តើអ្វីខ្លះរួមបញ្ចូលក្នុងប្រាក់បៀវត្ស? | ១ |
| តើអ្វីខ្លះមិនរួមបញ្ចូលក្នុងប្រាក់បៀវត្ស? | ២ |
| តើអ្វីខ្លះអនុញ្ញាតឲ្យកាត់កងចេញពីពន្ធលើប្រាក់បៀវត្ស? | ៣ |
| តើពន្ធលើប្រាក់បៀវត្សត្រូវគណនាដូចម្តេច? | ៤ |
| តើអត្ថប្រយោជន៍បន្ថែមត្រូវបានយកពន្ធដូចម្តេច? | ៥ |
| តើអ្វីខ្លះរួមបញ្ចូលក្នុងអត្ថប្រយោជន៍បន្ថែម? | ៥ |
| តើអ្នកជាប់ពន្ធនិវាសនជនទទួលបានឥណទានពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពបរទេសដែរឬទេ? | ៦ |
| សម្រាប់ទឹកប្រាក់ដែលបើកឲ្យនិយោជិតជាប្រាក់ដុល្លារអាមេរិក តើអត្រាប្តូរប្រាក់ត្រូវបានកំណត់យ៉ាងដូចម្តេច? | ១២ |
| តើពន្ធលើប្រាក់បៀវត្ស និងអត្ថប្រយោជន៍បន្ថែមត្រូវបង់នៅពេលណា និងរបៀបណា? | ១២ |
| សំណួរ | ១៣ |
| អាសយដ្ឋានទំនាក់ទំនង | ១៣ |

## តើពន្ធលើប្រាក់បៀវត្សគឺជាអ្វី?

ពន្ធលើប្រាក់បៀវត្ស គឺជាពន្ធប្រចាំខែដែលត្រូវកាត់ទុកដោយនិយោជកពីប្រាក់បៀវត្សរបស់និយោជិតដែលបំពេញការងារ។

- *អ្នកជាប់ពន្ធនិវាសនជន* ពន្ធត្រូវកាត់ទុកពីប្រាក់បៀវត្សប្រភពកម្ពុជា និង ពីប្រាក់បៀវត្សប្រភពបរទេស។
- *អ្នកជាប់ពន្ធអនិវាសនជន* ពន្ធត្រូវកាត់ទុកពីប្រាក់បៀវត្សប្រភពកម្ពុជា។

## តើនរណាជាអ្នកជាប់ពន្ធនិវាសនជន?

អ្នកជាប់ពន្ធនិវាសនជន គឺជាបុគ្គលដែលមានៈ

- លំនៅដ្ឋាន ឬកន្លែងស្នាក់នៅអចិន្ត្រៃយ៍ក្នុងប្រទេសកម្ពុជា ឬ
- មានវត្តមានក្នុងប្រទេសកម្ពុជាច្រើនជាង១៨២ថ្ងៃ ក្នុងរយៈពេល ១២ខែ នៃការបញ្ចប់ឆ្នាំសារពើពន្ធចរន្ត/ឆ្នាំជាប់ពន្ធចរន្ត។

## តើនរណាជាអ្នកជាប់ពន្ធអនិវាសនជន?

អ្នកជាប់ពន្ធអនិវាសនជន គឺជាបុគ្គលដែលមិនមែនជាអ្នកជាប់ពន្ធនិវាសនជន និងទទួលប្រាក់បៀវត្សប្រភពកម្ពុជា។

## តើអ្វីខ្លះរួមបញ្ចូលក្នុងប្រាក់បៀវត្ស?

ប្រាក់បៀវត្សសំដៅដល់បៀវត្ស លាភការ ប្រាក់បំណាច់ បុព្វលាភ ប្រាក់ម៉ោងបន្ថែម ប្រាក់ប៉ះប៉ូវនានា និងអត្ថប្រយោជន៍បន្ថែមដែលបានទូទាត់

ដល់និយោជិត ឬដែលបានទូទាត់ដើម្បីជាប្រយោជន៍ផ្ទាល់ ឬប្រយោល ដល់និយោជិតចំពោះការបំពេញសកម្មភាពបម្រើការងារ។

**តើអ្វីខ្លះមិនរួមបញ្ចូលក្នុងប្រាក់បៀវត្ស**?

- ប្រាក់សំណងដោយពិតប្រាកដនូវចំណាយខាងវិជ្ជាជីវៈ ដែលបានចាយដោយនិយោជិតតាមសេចក្តីបង្គាប់ និងសម្រាប់ជាផលប្រយោជន៍នៃនិយោជក។
- ប្រាក់សំណងសម្រាប់ការបញ្ឈប់ការងារ ស្របតាមក្របខ័ណ្ឌនៃច្បាប់ស្តីពីការងារ។
- ចំណាយបន្ថែមស្របតាមលក្ខណៈសង្គម ដែលមានចែងក្នុងច្បាប់ការងារ។
- ឯកសណ្ឋានពិសេស ឬសម្ភារៈវិជ្ជាជីវៈដែលមិនគិតថ្លៃ ឬមានតម្លៃទាប។
- ប្រាក់ឧបត្ថម្ភថេរសម្រាប់បេសកកម្ម និងចំណាយលើការធ្វើដំណើរជំនួសឲ្យការទូទាត់សងជាក់ស្តែង។
- ប្រាក់បៀវត្សរបស់មន្ត្រី និងបុគ្គលិក នៃបេសកកម្មកុងស៊ុល និងការទូតរបស់រដ្ឋាភិបាលក្រៅប្រទេស ដែលកាន់លិខិតឆ្លងដែនការទូត ឬផ្លូវការរបស់រដ្ឋាភិបាលបរទេស ដែលបានទទួលសិទ្ធិបំពេញមុខងារជាផ្លូវការរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

- ប្រាក់បៀវត្សរបស់តំណាងមន្ត្រី និងបុគ្គលិករបស់អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលផ្សេងទៀត ដែលបានទទួលសិទ្ធិបំពេញមុខងារផ្លូវការរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ប្រាក់បៀវត្សរបស់សមាជិករដ្ឋសភា និងព្រឹទ្ធសភាជាតិ។

## តើអ្វីខ្លះអនុញ្ញាតឲ្យកាត់កងចេញពីពន្ធលើប្រាក់បៀវត្ស?

- ចំនួនទឹកប្រាក់ដែលកាត់ទុកអនុលោមតាមច្បាប់ស្ដីពីការងារដើម្បីបង្កើតមូលនិធិសោធននិវត្តន៍ និងរក្សានូវសុខុមាលភាពសង្គម។
- ប្រាក់ឥណទានសម្រាប់និយោជិតដែលសងរួចរាល់ ឬប្រាក់បុរេប្រទានដែលជាប់ពន្ធលើប្រាក់បៀវត្សពីមុន។
- ការកាត់កងទឹកប្រាក់ចំនួន៧៥.០០០រៀល សម្រាប់កូននៅក្នុងបន្ទុករបស់និយោជិតជានិវាសនជន។ កូននៅក្នុងបន្ទុកត្រូវមានអាយុមិនលើសពី១៤ឆ្នាំ លើកលែងតែសិស្ស ឬនិស្សិតដែលរៀនពេញម៉ោង និងមានអាយុមិនលើសពី២៥ឆ្នាំ។ មានតែឪពុក ឬម្ដាយតែម្នាក់គត់ដែលមានសិទ្ធិទទួលបានការកាត់កងនូវចំនួនទឹកប្រាក់ទាំងនោះ។
- ក្នុងករណីប្ដីជានិយោជិតនិវាសនជន ការកាត់កងចេញនូវចំនួនទឹកប្រាក់៧៥.០០០រៀល សម្រាប់សហព័ទ្ធ(ស្ត្រី) ដែលធ្វើតែជាមេផ្ទះប៉ុណ្ណោះ។

## **តើពន្ធលើប្រាក់បៀវត្សត្រូវគណនាដូចម្តេច?**

សូមមើលតារាងខាងក្រោមនេះ៖

| តារាង១. ការគណនាពន្ធលើប្រាក់បៀវត្ស - និវាសនជនកម្ពុជា | |
|---|---|
| ប្រាក់បៀវត្សប្រចាំខែ (រៀល) | **វិធីគណនាប្រាក់ពន្ធ** |
| ០ ទៅ ៥០០.០០០ | ០ |
| ៥០០.០០១ ទៅ ១.២៥០.០០០ | ប្រាក់ពន្ធ= (មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស X ៥%) - ២៥,០០០ |
| ១.២៥០.០០១ ទៅ ៨.៥០០.០០០ | ប្រាក់ពន្ធ= (មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស X ១០%) - ៨៧,៥០០ |
| ៨.៥០០.០០១ ទៅ ១២.៥០០.០០០ | ប្រាក់ពន្ធ= (មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស X ១៥%) - ៥១២,៥០០ |
| ១២.៥០០.០០១ ឡើងទៅ | ប្រាក់ពន្ធ= (មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស X ២០%) - ១,១៣៧,០០០ |

| តារាង២. ការគណនាពន្ធលើប្រាក់បៀវត្ស - អនិវាសនជនកម្ពុជា | |
|---|---|
| ប្រាក់បៀវត្សប្រចាំខែ (រៀល) | **វិធីគណនាប្រាក់ពន្ធ** |
| ០ ឡើងទៅ | ២០% នៃប្រាក់បៀវត្ស |

## តើអត្ថប្រយោជន៍បន្ថែមត្រូវបានគិតពន្ធដូចម្តេច?

សូមមើលតារាងខាងក្រោមនេះ ៖

| តារាង៣.ការគណនាពន្ធ- និវាសនជន និង អនិវាសនជនកម្ពុជា | |
|---|---|
| ប្រាក់បៀវត្សប្រចាំខែ (រៀល) | ពន្ធ |
| 0 ឡើងទៅ | ២០%នៃចំនួនទឹកប្រាក់ |

## តើអ្វីខ្លះរួមបញ្ចូលក្នុងអត្ថប្រយោជន៍បន្ថែម?

អត្ថប្រយោជន៍បន្ថែមរួមមាន ៖

- ការប្រើប្រាស់យានយន្ត ប្រសិនបើនិយោជិតអាចយកយានយន្តនោះមកផ្ទះនៅពេលយប់ និងប្រើប្រាស់សម្រាប់គោលបំណងផ្ទាល់ខ្លួន។
- ចំណីអាហារដែលផ្តល់ឲ្យនិយោជិតទទួលទាន។
- ផ្ទះសំបែងដែលផ្តល់ឲ្យនិយោជិតស្នាក់នៅ (រាប់បញ្ចូលទាំងការចំណាយលើសេវាសាធារណៈ និងអ្នកបម្រើតាមផ្ទះ)។
- ប្រាក់កម្ចីដែលមានអត្រាការប្រាក់ទាបជាងអត្រាការប្រាក់កម្ចីលើទីផ្សារ។
- អប្បហារលើការលក់ទំនិញ-សេវា។
- ជំនួយផ្នែកអប់រំសម្រាប់និយោជិតដែលមិនមែនជាចំណែកណាមួយនៃកម្មវិធីបណ្តុះបណ្តាលទាក់ទិនផ្ទាល់ទៅនឹងការបំពេញការងាររបស់និយោជិតនោះ។
- ជំនួយផ្នែកអប់រំសម្រាប់កូនរបស់និយោជិត។

- ការបង់បុព្វលាភធានារ៉ាប់រងលើសុខភាព ឬធានារ៉ាប់រងលើអាយុជីវិត លើកលែងតែនិយោជិតទាំងអស់ទទួលបាននូវអត្ថ-ប្រយោជន៍ដូចៗគ្នា ដោយគ្មានបែងចែកតាមតួនាទី ឬមុខងារ។
- ការឧបត្ថម្ភលើចំណាយដែលមិនសមហេតុផល និងមិនចាំបាច់សម្រាប់អាជីវកម្មរបស់និយោជក។
- ការរួមវិភាគទានមូលនិធិសុខុមាលភាព សង្គមដែលលើសពីចំនួនដែលតម្រូវដោយច្បាប់។
- ការរួមវិភាគទានប្រាក់សោធននិវត្តន៍ដែលលើសពី១០%នៃប្រាក់បៀវត្ស (ដោយមិនរាប់បញ្ចូលអត្ថប្រយោជន៍បន្ថែម)។
- ការចំណាយលើការលំហែកំសាន្ត ឬវិស្សមកាលដែលមិនពាក់ព័ន្ធនឹងសកម្មភាពការងារ។

តម្លៃនៃអត្ថប្រយោជន៍បន្ថែម គឺជាតម្លៃទីផ្សាររួមទាំងពន្ធ-អាករទាំងអស់នៃអត្ថប្រយោជន៍បន្ថែមដែលបានផ្តល់ឲ្យ។

## តើអ្នកជាប់ពន្ធនិវាសនជនទទួលបានឥណទានពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពបរទេសដែរឬទេ?

ឥណទានពន្ធសម្រាប់ប្រាក់ពន្ធលើប្រាក់បៀវត្សត្រូវបានអនុញ្ញាត លុះត្រាតែមានចំនួនតិចជាងគេក្នុងចំណោម៖

- ប្រាក់ពន្ធដែលបានបង់ជាក់ស្តែងនៅប្រទេសក្រៅនោះ ឬ
- ចំនួនដែលបានយកមកពីប្រាក់ពន្ធលើប្រាក់បៀវត្សសរុបពីគ្រប់ប្រភពក្នុងរយៈពេលជាមួយគ្នា ដែលគណនាតាមអត្រាកំណើនតាមថ្នាក់តាមមាត្រា៤៧ នៃចសព ទៅគុណនឹងផល

ចែករវាងប្រាក់បៀវត្សដែលបានទទួលនៅប្រទេសក្រៅនោះ

និងប្រាក់បៀវត្សសរុបពីគ្រប់ប្រភព។

**ឧទាហរណ៍ទី១** ៖ លោក **សុខ** ជានិវាសនជនប្រទេសកម្ពុជាទទួលបានប្រាក់បៀវត្ស

-ចំនួន ១០.០០០.០០០រៀល នៅប្រទេសកម្ពុជា

-ចំនួន ៣.០០០.០០០រៀល នៅប្រទេស **ក** ជាប់ពន្ធតាមអត្រាពន្ធ២០% ស្មើនឹងប្រាក់ពន្ធ ៦០០.០០០រៀល

-ចំនួន ២.០០០.០០០ រៀល នៅប្រទេស **ខ** ជាប់ពន្ធតាមអត្រាពន្ធ១៥% ស្មើនឹងប្រាក់ពន្ធ ៣០០.០០០រៀល

*ឥណទានពន្ធសម្រាប់ប្រាក់ពន្ធលើប្រាក់បៀវត្ស៖*

*របៀបគណនា៖*

*ប្រាក់បៀវត្សសរុបពីគ្រប់ប្រភព*

*= ១០.០០០.០០០ + ៣.០០០.០០០ + ២.០០០.០០០*

*=១៥.០០០.០០០ រៀល*

*ពន្ធលើប្រាក់បៀវត្សសរុបនៅកម្ពុជា*

*=(១៥.០០០.០០០ X ២០%) – ១.១៣៧.០០០*

*=១.៨៦៣.០០០ រៀល*

*ពន្ធលើប្រាក់បៀវត្សនៅកម្ពុជាចំពោះចំណូលពីប្រទេស **ក***

*=១.៨៦៣.០០០ X (៣.០០០.០០០/១៥.០០០.០០០)*

*=៣៧២.៦០០ រៀល*

*ករណីខាងលើនេះបង្ហាញថា ពន្ធលើប្រាក់បៀវត្សនៅកម្ពុជា (៣៧២.៦០០រៀល) ទាបជាងពន្ធលើប្រាក់បៀវត្សដែលបានបង់ជាក់ស្តែងនៅប្រទេស **ក** (៦០០.០០០រៀល)។ ឥណទានពន្ធលើប្រាក់បៀវត្សដែលអនុញ្ញាតឲ្យកាត់កងបានគឺ ៣៧២.៦០០រៀល។*

*ពន្ធលើប្រាក់បៀវត្សនៅកម្ពុជាចំពោះចំណូលពីប្រទេស* ***ខ***

*=១.៨៦៣.000 X (២.000.000/១៥.000.000)*

*=២៤៨.៤00 រៀល*

*ករណីខាងលើនេះបង្ហាញថា ពន្ធលើប្រាក់បៀវត្សនៅកម្ពុជា (២៤៨.៤00រៀល) ទាបជាង ពន្ធលើប្រាក់បៀវត្សនៅប្រទេស* ***ខ*** *(៣00.000រៀល)។ ឥណទានពន្ធលើប្រាក់បៀវត្សដែលអនុញ្ញាតឲ្យកាត់កងបានគឺ ២៤៨.៤00រៀល ។*

*ដូច្នេះប្រាក់ពន្ធត្រូវបង់នៅប្រទេសកម្ពុជា បន្ទាប់ពីការកាត់កងឥណទានពន្ធ*

*=ប្រាក់ពន្ធត្រូវបង់នៅប្រទេសកម្ពុជាមិនទាន់កាត់កងឥណទានពន្ធ – (ពន្ធលើប្រាក់បៀវត្សនៅកម្ពុជាចំពោះចំណូលពីប្រទេស* ***ក*** *+ ពន្ធលើប្រាក់បៀវត្សនៅកម្ពុជាចំពោះចំណូលពីប្រទេស* ***ខ****)*

*=១.៨៦៣.000 – (៣៧២.៦00 + ២៤៨.៤00)*

*=**១.២៤២.000 រៀល***

**ឧទាហរណ៍ទី២** ៖ លោក **សុខ** ជានិវាសនជនប្រទេសកម្ពុជាទទួលបានប្រាក់បៀវត្ស

-ចំនួន ១0.000.000រៀល នៅប្រទេសកម្ពុជា

-ចំនួន ៣.000.000រៀល នៅប្រទេស **ក** ជាប់ពន្ធតាមអត្រាពន្ធ១0% ស្មើនឹងប្រាក់ពន្ធ ៣00.000រៀល

-ចំនួន ២.000.000រៀល នៅប្រទេស **ខ** ជាប់ពន្ធតាមអត្រាពន្ធ១0% ស្មើនឹងប្រាក់ពន្ធ ២00.000រៀល

*ឥណទានពន្ធសម្រាប់ប្រាក់ពន្ធលើប្រាក់បៀវត្ស៖*

*របៀបគណនា៖*

ប្រាក់បៀវត្សសរុបពីគ្រប់ប្រភព

= ១០.០០០.០០០ + ៣.០០០.០០០ + ២.០០០.០០០

=១៥.០០០.០០០រៀល

ពន្ធលើប្រាក់បៀវត្សសរុបនៅកម្ពុជា

=(១៥.០០០.០០០ X ២០%) – ១.១៣៧.០០០

=១.៨៦៣.០០០រៀល

ពន្ធលើប្រាក់បៀវត្សនៅកម្ពុជាចំពោះចំណូលពីប្រទេស **ក**

=១.៨៦៣.០០០ X (៣.០០០.០០០/១៥.០០០.០០០)

=៣៧២.៦០០រៀល

ករណីខាងលើនេះបង្ហាញថា ពន្ធលើប្រាក់បៀវត្សនៅប្រទេស **ក** (៣០០.០០០រៀល) ទាបជាង ពន្ធលើប្រាក់បៀវត្សនៅកម្ពុជា (៣៧២.៦០០រៀល)។ ឥណទានពន្ធលើប្រាក់បៀវត្សដែលអនុញ្ញាតឲ្យកាត់កងបានគឺ ៣០០.០០០រៀល។

ពន្ធលើប្រាក់បៀវត្សនៅកម្ពុជាចំពោះចំណូលពីប្រទេស **ខ**

=១.៨៦៣.០០០ X (២.០០០.០០០/១៥.០០០.០០០)

=២៤៨.៤០០រៀល

ករណីខាងលើនេះបង្ហាញថា ពន្ធលើប្រាក់បៀវត្សនៅប្រទេស **ខ** (២០០.០០០រៀល) ទាបជាង ពន្ធលើប្រាក់បៀវត្សនៅកម្ពុជា (២៤៨.៤០០រៀល)។ ឥណទានពន្ធលើប្រាក់បៀវត្សដែលអនុញ្ញាតឲ្យកាត់កងបានគឺ ២០០.០០០រៀល។

ដូច្នេះប្រាក់ពន្ធត្រូវបង់នៅប្រទេសកម្ពុជា បន្ទាប់ពីការកាត់កងឥណទានពន្ធ

*=ប្រាក់ពន្ធត្រូវបង់នៅប្រទេសកម្ពុជាមិនទាន់កាត់កងឥណទានពន្ធ*
*– (ពន្ធលើប្រាក់បៀវត្សនៅប្រទេស **ក** + ពន្ធលើប្រាក់បៀវត្សនៅ*
*ប្រទេស **ខ**)*

*=១.៨៦៣.០០០ – (៣០០.០០០ + ២០០.០០០)*

***=១.៣៦៣.០០០ រៀល***

**ឧទាហរណ៍ទី៣** ៖ លោក **សុខ** ជានិវាសនជនប្រទេសកម្ពុជាទទួលបាន ប្រាក់បៀវត្ស

-ចំនួន ១០.០០០.០០០ រៀល នៅប្រទេសកម្ពុជា

-ចំនួន ៣.០០០.០០០ រៀល នៅប្រទេស **ក** ជាប់ពន្ធតាមអត្រាពន្ធ២០% ស្មើនឹងប្រាក់ពន្ធ ៦០០.០០០ រៀល

-ចំនួន ២.០០០.០០០ រៀល នៅប្រទេស **ខ** ជាប់ពន្ធតាមអត្រាពន្ធ១០% ស្មើនឹងប្រាក់ពន្ធ ២០០.០០០ រៀល

*ឥណទានពន្ធសម្រាប់ប្រាក់ពន្ធលើប្រាក់បៀវត្ស៖*

*របៀបគណនា៖*

*ប្រាក់បៀវត្សសរុបពីគ្រប់ប្រភព*

*= ១០.០០០.០០០ + ៣.០០០.០០០ + ២.០០០.០០០*

*=១៥.០០០.០០០ រៀល*

*ពន្ធលើប្រាក់បៀវត្សសរុបនៅកម្ពុជា*

*=(១៥.០០០.០០០ X ២០%) - ១.១៣៧.០០០*

*=១.៨៦៣.០០០ រៀល*

*ពន្ធលើប្រាក់បៀវត្សនៅកម្ពុជាចំពោះចំណូលពីប្រទេស **ក***

*=១.៨៦៣.០០០ X (៣.០០០.០០០/១៥.០០០.០០០)*

*=៣៧២.៦០០ រៀល*

*ករណីខាងលើនេះបង្ហាញថា ពន្ធលើប្រាក់បៀវត្សនៅប្រទេស **កម្ពុជា** (៣៧២.៦០០រៀល) ទាបជាង ពន្ធលើប្រាក់បៀវត្សនៅប្រទេស **ក** (៦០០.០០០រៀល)។ ឥណទានពន្ធលើប្រាក់បៀវត្សដែលអនុញ្ញាតឲ្យកាត់កងបានគឺ ៣៧២.៦០០រៀល។*

*ពន្ធលើប្រាក់បៀវត្សនៅកម្ពុជាចំពោះចំណូលពីប្រទេស **ខ***

*=១.៨៦៣.០០០ X (២.០០០.០០០/១៥.០០០.០០០)*

*=២៤៨.៤០០ រៀល*

*ករណីខាងលើនេះបង្ហាញថា ពន្ធលើប្រាក់បៀវត្សនៅប្រទេស **ខ** (២០០.០០០រៀល) ទាបជាង ពន្ធលើប្រាក់បៀវត្សនៅកម្ពុជាចំពោះចំណូលពីប្រទេស **ខ** (២៤៨.៤០០រៀល)។ ឥណទានពន្ធលើប្រាក់បៀវត្សដែលអនុញ្ញាតឲ្យកាត់កងបានគឺ ២០០.០០០រៀល។*

*ដូច្នេះប្រាក់ពន្ធត្រូវបង់នៅប្រទេសកម្ពុជា បន្ទាប់ពីការកាត់កងឥណទានពន្ធ*

*=ប្រាក់ពន្ធត្រូវបង់នៅប្រទេសកម្ពុជាមិនទាន់កាត់កងឥណទានពន្ធ –(ពន្ធលើប្រាក់បៀវត្សនៅកម្ពុជាចំពោះចំណូលពីប្រទេស **ក** + ពន្ធលើប្រាក់បៀវត្សនៅប្រទេស **ខ**)*

*=១.៨៦៣.០០០ – (៣៧២.៦០០ + ២០០.០០០)*

*=<u>**១.២៩០.៤០០រៀល**</u>*

ឥណទានពន្ធលើប្រាក់បៀវត្សត្រូវកំណត់ដាច់ដោយឡែកសម្រាប់ប្រាក់បៀវត្សប្រភពបរទេសនីមួយៗ ហើយឯកសារទាំងអស់ត្រូវបញ្ជូនមកកាន់អគ្គនាយកដ្ឋានពន្ធដារ៖

- សេចក្តីបញ្ជាក់របស់និយោជក ឬកិច្ចសន្យាបម្រើការងារដែលមានបញ្ជាក់លម្អិតអំពីការងារបានបំពេញ កាលបរិច្ឆេទ និងចំនួនប្រាក់បៀវត្សបានទទួលសម្រាប់ការងារនៅប្រទេសក្រៅ
- ច្បាប់ចម្លងនៃទម្រង់ឯកសារដែលនិយោជកបានដាក់ជូនរដ្ឋបាលសារពើពន្ធប្រទេសក្រៅនោះ ដើម្បីបង់ប្រាក់ពន្ធ
- បង្កាន់ដៃទទួលប្រាក់ពន្ធបរទេសដែលរដ្ឋបាលសារពើពន្ធប្រទេសក្រៅបានចេញឲ្យ។

## សម្រាប់ទឹកប្រាក់ដែលបើកឲ្យនិយោជិតជាប្រាក់ដុល្លារអាមេរិក តើអត្រាប្តូរប្រាក់ត្រូវបានកំណត់យ៉ាងដូចម្តេច?

ជារៀងរាល់ខែ អគ្គនាយកដ្ឋានពន្ធដារចេញផ្សាយនូវអត្រាប្តូរប្រាក់ផ្លូវការសម្រាប់គណនាពន្ធលើប្រាក់បៀវត្ស។

## តើពន្ធលើប្រាក់បៀវត្ស និងអត្ថប្រយោជន៍បន្ថែមត្រូវបង់នៅពេលណា និងរបៀបណា?

រៀងរាល់ខែ និយោជកត្រូវកាត់ទុកប្រាក់ពន្ធនៅពេលបើកប្រាក់បៀវត្ស (សាច់ប្រាក់ ឬវត្ថុ) ជូននិយោជិត ដោយភ្ជាប់ជាមួយតារាងលម្អិតអំពីពន្ធលើប្រាក់បៀវត្ស (ប្រតិវេទន៍ពន្ធ) និងបង់ប្រាក់ពន្ធយ៉ាងយឺតបំផុតនៅថ្ងៃទី១៥ នៃខែបន្ទាប់។ ប្រតិវេទន៍ពន្ធត្រូវធ្វើលើទម្រង់លិខិតប្រកាស ពបវ-០១។ ការបង់ពន្ធត្រូវធ្វើឡើងនៅនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ សាខាពន្ធដារខណ្ឌនៃរាជធានីភ្នំពេញ និងសាខាពន្ធដារខេត្ត ដែលក្រុមហ៊ុនបានចុះបញ្ជី។

**សំណួរ**? ប្រសិនបើលោកអ្នកមានចម្ងល់ ឬសំណួរផ្សេងៗ ដែលពុំទាន់ឆ្លើយនៅក្នុងឯកសារបោះពុម្ពផ្សាយនេះ សូមមើលទម្រង់លិខិតប្រកាស ពបវ-០១ ឬសូមទាក់ទងមកកាន់នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ សាខាពន្ធដារខណ្ឌ នៃរាជធានីភ្នំពេញ និងសាខាពន្ធដារខេត្តណាមួយ ដែលក្រុមហ៊ុនបានចុះបញ្ជី។

## អាសយដ្ឋានទំនាក់ទំនង

### អគ្គនាយកដ្ឋានពន្ធដារ

៥២២-៥២៤ កែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥)
សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ៖ (៨៥៥) ២៣ ៨៨៦ ៧០៨
សារអេឡិចត្រូនិក៖ info@tax.gov.kh

### នាយកដ្ឋាន សេវាអ្នកជាប់ពន្ធ និងបំណុលពន្ធ

សារអេឡិចត្រូនិក៖ dtsta@tax.gov.kh

### នាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ

សារអេឡិចត្រូនិក៖ dlls@tax.gov.kh

### នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ

សារអេឡិចត្រូនិក៖ dlt@tax.gov.kh

**សាខាពន្ធដារ ខណ្ឌឫស្សីកែវ**

ផ្ទះលេខ១០២ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

សារអេឡិចត្រូនិក៖ russeykeo@tax.gov.kh

**សាខាពន្ធដារ ខណ្ឌដូនពេញ**

ផ្ទះលេខ១៦៦ ផ្លូវលេខ១៣០ សង្កាត់ផ្សារកណ្ដាលទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

សារអេឡិចត្រូនិក៖ daunpenh@tax.gov.kh

**សាខាពន្ធដារ ខណ្ឌ៧មករា**

ផ្ទះលេខ២៥បេ ផ្លូវសម្ដេចប៉ាន(២១៤) សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ

សារអេឡិចត្រូនិក៖ 7makara@tax.gov.kh

**សាខាពន្ធដារ ខណ្ឌមានជ័យ**

អគារលេខ៣៤សេ ផ្លូវ៣៦១កែង៦៤២ សង្កាត់ច្បារអំពៅ១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

សារអេឡិចត្រូនិក៖ meanchey@tax.gov.kh

**សាខាពន្ធដារ ខណ្ឌចំការមន**

ផ្ទះលេខ២៨ ផ្លូវលេខ៤៨៨ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ

សារអេឡិចត្រូនិក៖ chamkarmorn@tax.gov.kh

**សាខាពន្ធដារ ខណ្ឌទួលគោក**

ផ្ទះលេខ២៤ ផ្លូវ២៨៧ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានី ភ្នំពេញ

សារអេឡិចត្រូនិក៖ tuolkork@tax.gov.kh

**សាខាពន្ធដារ ខណ្ឌពោធិ៍សែនជ័យ**

ផ្ទះលេខ២៣៤ ផ្លូវលេខ២០០៧ សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

សារអេឡិចត្រូនិក៖ dangkor@tax.gov.kh

**សាខាពន្ធដារ ខេត្តកណ្តាល**

ផ្ទះលេខ១០៣ ផ្លូវលេខ១០៨ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល

សារអេឡិចត្រូនិក៖ kandal@tax.gov.kh

**សាខាពន្ធដារ ខេត្តកំពង់ចាម**

ផ្ទលេខ៥ ផ្លូវខេមរភូមិន្ទ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម

សារអេឡិចត្រូនិក៖ kampongcham@tax.gov.kh

**សាខាពន្ធដារ ខេត្តបាត់ដំបង**

ផ្ទះលេខ២ ផ្លូវជាតិលេខ៥ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង

សារអេឡិចត្រូនិក៖ battambang@tax.gov.kh

**សាខាពន្ធដារ ខេត្តព្រៃវែង**

ភូមិលេខ២ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង

សារអេឡិចត្រូនិក៖ preyveng@tax.gov.kh

**សាខាពន្ធដារ ខេត្តសៀមរាប**

ផ្លូវជាតិលេខ៦ ភូមិសាលាកន្សែង សង្កាត់ស្វាយដង្គុំ ក្រុងសៀមរាប ខេត្តសៀមរាប

សារអេឡិចត្រូនិក៖ siamreap@tax.gov.kh

**សាខាពន្ធដារ ខេត្តកំពង់ធំ**

ផ្លូវលេខ៦ ភូមិត្រឡាំងលិច សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ

សារអេឡិចត្រូនិក៖ kampong_thom@tax.gov.kh

**សាខាពន្ធដារ ខេត្តតាកែវ**

ផ្លូវលេខ៣ ភូមិ១ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ

សារអេឡិចត្រូនិក៖ takeo@tax.gov.kh

**សាខាពន្ធដារ ខេត្តស្វាយរៀង**

ផ្លូវភូមិរោងបន្លែ សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង

សារអេឡិចត្រូនិក៖ svayrieng@tax.gov.kh

**សាខាពន្ធដារ ខេត្តពោធិ៍សាត់**

ផ្លូវជាតិលេខ៥ សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់

សារអេឡិចត្រូនិក៖ pursat@tax.gov.kh

**សាខាពន្ធដារ ខេត្តកំពង់ឆ្នាំង**

ភូមិឃ្លាំងប្រាក់ ឃុំប្អេរ ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង

សារអេឡិចត្រូនិក៖ kampongchhnang@tax.gov.kh

**សាខាពន្ធដារ ខេត្តកំពង់ស្ពឺ**

ផ្លូវជាតិលេខ៤ ភូមិត្រពាំងលើក សង្កាត់រកាធំ ក្រុងច្បារមន
ខេត្តកំពង់ស្ពឺ

សារអេឡិចត្រូនិក៖ kampongspeu@tax.gov.kh

**សាខាពន្ធដារ ខេត្តកំពត**

ភូមិ១ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត

សារអេឡិចត្រូនិក៖ kampot@tax.gov.kh

**សាខាពន្ធដារ ខេត្តព្រះសីហនុ**
ផ្លូវ២៨មិថុនា សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
សារអេឡិចត្រូនិះ preahsihanouk@tax.gov.kh

**សាខាពន្ធដារ ខេត្តកោះកុង**
ភូមិ២ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង
សារអេឡិចត្រូនិកៈ kohkong@tax.gov.kh

**សាខាពន្ធដារ ខេត្តព្រះវិហារ**
ភូមិកណ្តាល សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ
សារអេឡិចត្រូនិកៈ preahvihear@tax.gov.kh

**សាខាពន្ធដារ ខេត្តក្រចេះ**
ផ្ទះលេខ៧៣ សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ
សារអេឡិចត្រូនិកៈ kratie@tax.gov.kh

**សាខាពន្ធដារ ខេត្តរតនៈគិរី**
ផ្លូវភូមិអូរកន្សែង សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនៈគិរី
សារអេឡិចត្រូនិកៈ ratanakiri@tax.gov.kh

**សាខាពន្ធដារ ខេត្តមណ្ឌលគិរី**
ភូមិកណ្តាល សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី
សារអេឡិចត្រូនិកៈ mondulkiri@tax.gov.kh

**សាខាពន្ធដារ ខេត្តបន្ទាយមានជ័យ**

ប្លុកU ភូមិក្បាលស្ពាន សង្កាត់ព្រះពន្លា ក្រុងសេរីសោភ័ណ
ខេត្តបន្ទាយមានជ័យ

សារអេឡិចត្រូនិក៖ banteaymeanchey@tax.gov.kh

**សាខាពន្ធដារ ខេត្តស្ទឹងត្រែង**

ផ្លូវភូមិស្ពានថ្ម សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង

សារអេឡិចត្រូនិក៖ stoengtreng@tax.gov.kh

**សាខាពន្ធដារ ខេត្តកែប**

ផ្លូវ៣៣A ភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប

សារអេឡិចត្រូនិក៖ kep@tax.gov.kh

**សាខាពន្ធដារ ខេត្តប៉ៃលិន**

ភូមិបឱនាវ សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន

សារអេឡិចត្រូនិក៖ pailin@tax.gov.kh

**សាខាពន្ធដារ ខេត្តឧត្តរមានជ័យ**

ភូមិឈូក សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ

សារអេឡិចត្រូនិក៖ odormeanchey@tax.gov.kh